**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៣ សរ

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍
ចូល
លេខ 390 គ.ន.អ
ថ្ងៃទី 28 ខែ06 ឆ្នាំ1997
ម៉ោង 8:00 នាទី

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ១៩៩៧

# សារាចរ

## ស្តីពីបែបបទ និងនីតិវិធីនៃការស្នើសុំរួចពន្ធឧបករណ៍សំភារៈនាំចូល ក្នុងក្របខ័ណ្ឌជំនួយឥតសំណង ឥណទាន និង ជំនួយមនុស្សធម៌

* * * * *

កន្លងមក រាជរដ្ឋាភិបាលបានពិនិត្យឃើញ មានការយឺតយ៉ាវខ្លះក្នុងការស្នើសុំ និងដោះស្រាយអោយរួចពន្ធនូវការនាំចូលឧបករណ៍ សំភារៈក្នុងក្របខ័ណ្ឌជំនួយឥតសំណង ឥណទាន និងជំនួយមនុស្សធម៌ ដែលជាមូលហេតុមួយធ្វើអោយការអនុវត្តន៍គំរោងការមួយចំនួន ប្រព្រឹត្តទៅមិនបានតាមកម្មវិធីដែលបានគ្រោងទុក។

ដើម្បីជំរុញល្បឿនក្នុងការស្នើសុំ និងដោះស្រាយអោយរួចពន្ធនូវការនាំចូលឧបករណ៍ សំភារៈ ក្នុងក្របខ័ណ្ឌជំនួយឥតសំណង ឥណទាន និងជំនួយមនុស្សធម៌ រាជរដ្ឋាភិបាលបានកំណត់បែបបទ និងនីតិវិធីដូចខាងក្រោម៖

១– ស្ថាប័នអនុវត្តគំរោងនានាត្រូវរៀបចំតារាងបញ្ជី (Master List) ឧបករណ៍ សំភារៈ នាំចូលសំរាប់ប្រើប្រាស់ក្នុងគំរោងការនីមួយៗ រួចផ្ញើជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ (គអក/ គជនា) ។

២– ចំពោះសំណើនាំចូលឧបករណ៍ សំភារៈរួចពន្ធសំរាប់អនុវត្តគំរោងការ ក្នុងក្របខ័ណ្ឌជំនួយឥតសំណង (ទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល) សាមីស្ថាប័នជាអ្នកអនុវត្តគំរោងការឬស្ថាប័នទទួលជំនួយ ត្រូវបំពេញទំរង់បែបបទស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសំរេចតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ។

៣– ចំពោះសំណើនាំចូលឧបករណ៍ សំភារៈរួចពន្ធ ក្នុងក្របខ័ណ្ឌឥណទាន និងជំនួយបច្ចេកទេសផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀង (ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក ...) សាមីស្ថាប័នអនុវត្តន៍គំរោងការត្រូវបំពេញទំរង់បែបបទស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សំរេច ។

៤– ចំពោះសំណើនាំចូលឧបករណ៍ សំភារៈរួចពន្ធ ក្នុងក្របខ័ណ្ឌជំនួយមនុស្សធម៌ សាមីស្ថាប័នទទួលជំនួយនោះ ត្រូវបំពេញទំរង់បែបបទស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សំរេច ។

៥–ឯកសារយោងសំខាន់ៗសំរាប់បំពេញបែបបទស្នើសុំមានដូចខាងក្រោម :

–កិច្ចព្រមព្រៀង ឬឯកសារដែលមានតំលៃប្រហាក់ប្រហែល

–បញ្ជីរាយនាមមុខទំនិញ Packing List

–វិក័យប័ត្រ Invoice

–អញ្ញាតប័ណ្ណ Bill of Loading

រាជរដ្ឋាភិបាលសូមស្ថាប័នទាំងអស់ យកចិត្តទុកដាក់ក្នុងការអនុវត្តន៍សារាចរនេះ អោយមានប្រសិទ្ធភាព ។

| | |
|---|---|
| ចម្លងជូន : | នាយករដ្ឋមន្ត្រីទី១     នាយករដ្ឋមន្ត្រីទី២ |
| –ខុទ្ទកាល័យព្រះមហាក្សត្រ | |
| –អគ្គលេខាធិការដ្ឋានរដ្ឋសភា | |
| –គ្រប់ក្រសួង –រដ្ឋលេខាធិការដ្ឋាន | |
| –ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ | នរោត្តម រណឫទ្ធិ     ហ៊ុន សែន |
| –ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២ | |
| –កាលប្បវត្តិ–ឯកសារ | |